ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែធ្នូ ឆ្នាំ២០២១

នៅក្នុងខែធ្នូ ឆ្នាំ២០២១នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ

-ទទួលជួបសវនាការជាមួយឯកឧត្តម **ង្វៀន សួនហ្វ៊ុក (NGUYEN XUAN PHUC)** ប្រធានរដ្ឋ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ទទួលជួបសវនាការសម្តែងការគួរសមជាមួយឯកឧត្តម **ផនខាំ វីផាវ៉ាន់ (Phan khan Viphavanh)** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-បានអនុញ្ញាតឱ្យឯកឧត្តម **ហ្សាក់ ប៉ឺឡេត (Jacques Pellet)** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មី នៃសាធារណរដ្ឋបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការ និងសម្តែងការគួរសម

-បានអនុញ្ញាតឱ្យឯកឧត្តម **ង្វៀង ហ៊ុយ តាំង (Nguyen Huy Tang)** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពទើបតែងតាំងថ្មី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការ និងសម្តែងការគួរសម

-បានអនុញ្ញាតឱ្យឯកឧត្តម **អាំផៃ ឃីនដាវង្ស (Amphay Kindavong)** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

-បានអនុញ្ញាតឱ្យឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ទើបតែងតាំងថ្មីប្រចាំនៅប្រទេសនានាចំនួន៣រូប ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ណែនាំមុននឹងចេញដំណើរទៅបំពេញភារកិច្ច។

ខ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ និងពិធីបូជាព្រះសព **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** ព្រះប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅទីមេរុខាងមុខវត្តបទុមវតីរាជវរារាម សង្កាត់ចតុមុខ ខណ្ឌដូនពេញ

-បានអញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ ជាកិត្តិយសដ៏ខ្ពង់ខ្ពស់ជូនឯកឧត្តម **ង្វៀន សួនហ៊្វុក (NGUYEN XUAN PHUC)** ប្រធានរដ្ឋ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ នៅព្រះរាជដំណាក់សិរីមង្គល ព្រះបរមរាជវាំង

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកស្រី **ស ស៊ន់** ដែលត្រូវជាបងស្រីបង្កើតសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានអញ្ជើញចូលរួមប្រកួតកីឡាវាយកូនគោល ( ពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីលើកទី៥ ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីលានវាយកូនគោល វឌ្ឍនហ្គោលរីស៊ត។

គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤៤ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ ភា អនុប្រធានទី១ ព្រឹទ្ធសភា**

ក-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ និងពិធីបូជាព្រះសព **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** ព្រះប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅទីមេរុខាងមុខវត្ត

បទុមវតីរាជវរារាម សង្កាត់ចតុមុខ ខណ្ឌដូនពេញ

-បានអញ្ជើញចូលរួមពីធីសម្ពោធវិមានកីឡដ្ឋាន នៃពហុកីឡាដ្ឋានជាតិមរតកតេជោ និងពិធីរាប់ថយក្រោយ៥០២ថ្ងៃ ដំណើរឆ្ពោះទៅកាន់ព្រឹត្តិការណ៍ប្រកួតកីឡាSEA Game-ASEAN Para Game ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានកីឡដ្ឋាន នៃពហុកីឡាដ្ឋានជាតិមរតកតេជោ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

**ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៦ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**ក-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ទាំង១២៧ឃុំ សង្កាត់ ចំនួន១១លើក នៅខេត្តកណ្តាល។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ និងពិធីបូជាព្រះសព **សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ** ព្រះប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅរាជធានីភ្នំពេញ

-ដឹកនាំគណៈប្រតិភូព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធ និងជាអធិបតីក្នុងពិធីបញ្ចុះសពលោកជំទាវ **ឱ សុខុម** សមាជិកាគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា និងជាសមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨

-បានអញ្ជើញចូលរួមពិធីបុណ្យខួប៧ថ្ងៃឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធមហាឧបាសកា **ស ស៊ិន** នៅគេហដ្ឋានរាជធានីភ្នំពេញ។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣០ច្បាប់។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់

ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

## ៤.១ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឈ្វេងយល់អំពីការវិវឌ្ឍ បញ្ហាប្រឈម និងចក្ខុវិស័យទៅមុខរបស់ក្រសួង ពិសេសគោលនយោបាយ សកម្មភាពអាទិភាពក្នុងបរិបទវិបត្តិជំងឺកូវីដ-១៩ ការស្តារសេដ្ឋកិច្ចឡើងវិញក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ និងវិធានការចំបាច់នានារបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានអញ្ជើញចុះបេសកកម្ម ដើម្បីតាមដាន និងជំរុញការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ និងឈ្វេងយល់អំពីសិទ្ធិទទួលបានសុខភាព ពិសេស ស្ត្រី និងកុមារក្នុងកំឡុងពេលមានវិបត្តិកូវីដ-១៩ នៅខេត្តបន្ទាយមានជ័យ

-បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីការប្រមូលព័ត៌មានការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តតាកែវ។

## ៤.២ មុខងារតំណាង

-បានអញ្ជើញប្រជុំពិភាក្សាការងារជាមួយលោក **ដារ៉ារិទ្ធ គឹមយាត** នាយប្រតិបត្តិនៃមជ្ឈមណ្ឌលវិទ្យាស្ថានសភាអាស៊ី តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មការច្បាប់ និងនីតិវិធីបោះឆ្នោតរាជធានីភ្នំពេញ ស្តីពីការងារត្រួតពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២១ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមវេទិកាសំណេះសំណាលការងារជាមួយក្រុមប្រឹក្សា ឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ស្តីពីការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងបញ្ហាប្រឈម តម្រូវការ និងសំណូមពរជុំវិញការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនដោយផ្តោតសំខាន់លើការងារផ្តល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណ-ប័ណ្ណសញ្ជាតិខ្មែរ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុ-កូលដ្ឋាន មូលនិធិឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មាន

សុវត្ថិភាព ក្រោមអធិបតីភាពឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នៅសាលប្រជុំសាលាស្រុកប្រាសាទបាគង ខេត្តសៀមរាប

-បានអញ្ជើញចូលរួមពិធីសំណេះសំណាល និងចែករំលែកបទពិសោធន៍ដំណើរឆ្ពោះទៅទទួលបានជោគជ័យ ក្នុងជីវិតភាពជាអ្នកដឹកនាំ ជូនដល់យុវតីសិស្សថ្នាក់ទី១២ នៃវិទ្យាល័យកំពង់ធំ ក្រោមអធិបតីភាពលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាប្រធានគណៈកម្មការទី៨ នៅខេត្តកំពង់ធំ

-បានអញ្ជើញជាវាគ្មិនក្នុងកម្មវិធីទស្សនកិច្ចសិក្សារបស់សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង ចំនួន១៩នាក់ ក្នុងគោលបំណង ដើម្បីស្វែងយល់អំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា និងដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា

-បានទទួលពាក្យបណ្ដឹងចំនួន១ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន១ករណី និងកំពុងពិនិត្យសិក្សាចំនួន៤ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន១ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្ដឹងពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន១២ករណី។

-អញ្ជើញគោរពវិញ្ញាណក្ខន្ធព្រះសព**សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ** ព្រះប្រធានឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងសពលោកជំទាវ **ឱ សុខុម** សមាជិកាគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃព្រឹទ្ធសភា និងជាសមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨

-បានអញ្ជើញចូលរួមក្នុងពិធីផ្លូវការផ្សេងៗចំនួន៤៨លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះមូលដ្ឋាន ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេស ចុះឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងការផ្ដល់សេវាសាធារណៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ការដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ព្រមទាំងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន

ចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗ ចំនួន១០២លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

### ៤.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំ និងវេទិកានានា តាមប្រព័ន្ធវីដេអូរួមមាន ៖ កិច្ចប្រជុំប្រចាំឆ្នាំលើកទី២៩ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (APPF-29) ផ្សាយចេញពីទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ, កិច្ចប្រជុំក្រុមការងារដើម្បីពិនិត្យ និងពិភាក្សាសេចក្តីព្រាង ស្តីពីការសើរើលក្ខន្តិកៈនៃសភាប្រើភាសាបារាំង (APF) ផ្សាយចេញពីទីក្រុងប៉ារីស សាធារណរដ្ឋបារាំង និងកិច្ចប្រជុំចំពោះកិច្ច (Ad-hoc) នៃវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិក ទទួលបន្ទុកសុខភាពពិភពលោក ក្រោមប្រធានបទ "COVID-19 និងការយកចិត្តទុកដាក់អំពីសុខមាលភាពបឋមនាពេលអនាគត"

-លោកជំទាវ **ទី បូរ៉ាស៊ី** បានអនុញ្ញាតឱ្យកញ្ញា **ដេង គន្ធា** ស្ត្រីខ្មែរដំបូងសិក្សាជំនាញវិស្វកម្ម វិទ្យាសាស្ត្រសម្ភារនៅសហរដ្ឋអាមេរិក ចូលជួបសម្តែងការគួរសម

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** បានអនុញ្ញាតឱ្យលោកជំទាវបណ្ឌិត **Devyani Khopra grade** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសម្តភាព នៃសាធារណរដ្ឋឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ និងទទួលជួបជាមួយក្រុមអ្នកវិនិយោគទុនមកពីប្រទេសចិន ដើម្បីស្វែងរកឱកាសវិនិយោគលើវិស័យអចលនទ្រព្យ កសិកម្ម កសិឧស្សាហកម្ម និងទេសចរណ៍

-ឯកឧត្តម **ឆាយ វណ្ណា** បានអញ្ជើញជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយលោក **Fahad Ur Reham** ភារធារីតំណាងស្ថានទូតសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន, ឯកឧត្តម **Sudirman Haseng** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌូនេស៊ី, លោកជំទាវ **Ayda Unlu** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋទួរគី, ឯកឧត្តម **Pengiran Kasmihan Bin**

**Pengiran Haji Tahir** ឯកអគ្គរាជទូតព្រុយណេ, ឯកឧត្តម **Eldin Hunaini MohdHashim** ឯកអគ្គរាជទូតម៉ាឡេស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីរឹតចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងសភាទាំងពីរ

-ឯកឧត្តម **អាយ ខន** បានអនុញ្ញាតឱ្យឯកឧត្តម **អាមផាយ គីនដាវង្ស** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា។

ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

*កិត្តិសង្គហបណ្ឌិត* **ទេព ងន**

*<u>ចម្លងជូន</u>*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*